ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០១៤ សព្វហ

# សេចក្តីប្រកាសព័ត៌មាន

## អំពីលទ្ធផលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ក្រសួងមហាផ្ទៃ ក្នុងឱកាសអញ្ជើញចូលរួមកម្មវិធីខួបអនុស្សាវរីយ៍៨០ឆ្នាំ ថ្ងៃប្រពៃណីកងកម្លាំងនគរបាលប្រជាជនវៀតណាម

កាលពីថ្ងៃទី ១៦-១៧ ខែសីហា ឆ្នាំ២០២៥ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ក្រសួងមហាផ្ទៃ អញ្ជើញបំពេញទស្សនកិច្ចដើម្បីចូលរួមកម្មវិធីខួបអនុស្សាវរីយ៍ ៨០ឆ្នាំ ថ្ងៃប្រពៃណីកងកម្លាំងនគរបាលវៀតណាម ប្រព្រឹត្តទៅនៅរដ្ឋធានីហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលព្រឹត្តិការណ៍នេះក៏មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងប្រតិភូមកពីក្រសួងមហាផ្ទៃ ក្រសួងសន្តិសុខសាធារណៈ និងស្ថាប័នអនុវត្តច្បាប់ នៃបណ្តាប្រទេសនានាក្នុងតំបន់អាស៊ាន និងក្រៅតំបន់ សរុបប្រមាណ ១៦ប្រទេស ។

បន្ទាប់ពីការចូលរួមក្នុងកម្មវិធីដ៏មហោឡារិកនៃខួបអនុស្សាវរីយ៍ ៨០ឆ្នាំ ថ្ងៃប្រពៃណីកងកម្លាំងនគរបាលវៀតណាម និងក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះ ឯកឧត្តម អភិសន្តិបណ្ឌិត **ស សុខា** បានជួបសម្តែងការគួរសម និងពិភាក្សាការងារទ្វេភាគីជាមួយ ឯកឧត្តម នាយឧត្តមសេនីយ៍ **វិល័យ ឡាខាំហ្វង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នារសៀលថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០២៥ ដែលលទ្ធផលសំខាន់ៗនៃជំនួប មានដូចតទៅ៖

- ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងក្រសួងទាំងពីរ រហូតមកដល់បច្ចុប្បន្ននេះ និងការប្រាស្រ័យទំនាក់ទំនងយ៉ាងសកម្ម តាមរយៈការផ្លាស់ប្តូរប្រតិភូទស្សនកិច្ចទៅវិញទៅមកជាបន្តបន្ទាប់ ព្រមទាំងបានសម្តែងនូវការអបអរសាទរចំពោះទំនាក់ទំនងដ៏ល្អគ្រប់កម្រិតរវាងថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ ដែលជាកត្តាជំរុញដល់កិច្ចសហប្រតិបត្តិការរឹងមាំរវាងក្រសួង ទាំងពីរ ។
- ឯកឧត្តម អភិសន្តិបណ្ឌិត **ស សុខា** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម នាយឧត្តមសេនីយ៍ **វិល័យ ឡាខាំហ្វង** ដែលបានដឹកនាំគណៈប្រតិភូអញ្ជើញចូលរួមខួបលើកទី៨០

ទិវាកំណើតនគរបាលជាតិកម្ពុជា កាលពីខែឧសភា នៅរាជធានីភ្នំពេញ កន្លងទៅនេះ ដែលស្តែងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹង និងពង្រីកនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងក្រសួងទាំងពីរ និងការជួយគាំទ្រគ្នាទៅវិញទៅមក កាន់តែសកម្មថែមទៀត ។

- ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** និង ឯកឧត្តម នាយឧត្តមសេនីយ៍ **វិល័យ ឡាខាំហ្វង** ក៏បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេសបទល្មើសគ្រឿងញៀន និងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលអាជ្ញាធរមានសមត្ថកិច្ច និងកងកម្លាំងអនុវត្តច្បាប់នៃភាគីទាំងពីរ បានយកចិត្តទុកដាក់អនុវត្តធ្វើឱ្យមានការវិវត្តប្រែប្រួលប្រកបដោយភាពវិជ្ជមាន ព្រមទាំងបានឯកភាពបន្តជំរុញកិច្ចសហប្រតិបត្តិការលើកិច្ចការនេះឱ្យកាន់តែសកម្ម និងខ្លាំងក្លាថែមទៀត ។

បន្ទាប់មក នារសៀលថ្ងៃដដែល ឯកឧត្តម អភិសន្តិបណ្ឌិត **ស សុខា** ក៏មានជំនួបជាមួយ ឯកឧត្តម ឧត្តមសេនីយ៍ឯក **លឿង តាមក្វាង** សមាជិកការិយាល័យនយោបាយ និងជារដ្ឋមន្ត្រីក្រសួងនគរបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម៖

- ឯកឧត្តម ឧត្តមសេនីយ៍ឯក **លឿង តាមក្វាង** បានសម្តែងនូវក្តីសោមនស្ស និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាននៃការអញ្ជើញរបស់ ឯកឧត្តម អភិសន្តិបណ្ឌិត **ស សុខា** ចូលរួមនៅក្នុងព្រឹត្តិការណ៍ដ៏មានអត្ថន័យរបស់នគរបាលប្រជាជនវៀតណាម ហើយចាត់ទុកដំណើរទស្សនកិច្ចនេះជាការរួមចំណែកដល់ការលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ កាន់តែសកម្មថែមទៀតរវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងនគរបាលវៀតណាម ។
- ឯកឧត្តម អភិសន្តិបណ្ឌិត **ស សុខា** ក៏បានថ្លែងនូវការអបអរសាទរចំពោះពិធីខួបលើកទី៨០ នៃថ្ងៃប្រពៃណីកងកម្លាំងនគរបាលប្រជាជនវៀតណាម ដែលទិវានេះឆ្លុះបញ្ចាំងអំពីសមិទ្ធផល និងស្នាដៃ ព្រមទាំងឆន្ទៈដ៏អង់អាចមោះមុតរបស់នគរបាល បម្រើក្នុងបុព្វហេតុជាតិ និងប្រជាជន ជាពិសេសនគរបាលប្រជាជនវៀតណាម បានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការស្តារ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេសវៀតណាម រហូតមកដល់បច្ចុប្បន្ននេះ ។
- ក្នុងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ ឯកឧត្តម អភិសន្តិបណ្ឌិត **ស សុខា** និង ឯកឧត្តម ឧត្តមសេនីយ៍ឯក **លឿង តាមក្វាង** បានឯកភាព និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរវាងអង្គភាពជំនាញក្រោមឱវាទនៃក្រសួងទាំងពីរ ដែលតែងផ្សាភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងគាំទ្រគ្នាទៅវិញទៅមក ក្នុងការងារប្រយុទ្ធប្រឆាំងបទល្មើសគ្រប់ប្រភេទយ៉ាងសកម្ម សំដៅថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈបានល្អប្រសើរសម្រាប់ប្រទេសទាំងពីរ ។

បន្ថែមពីលើនេះ ឯកឧត្តម អភិសន្តិបណ្ឌិត **ស សុខា** ក៏បានថ្លែងអំណរគុណចំពោះ ឯកឧត្តម នាយឧត្តមសេនីយ៍ **វិល័យ ឡាខាំហុង** និង ឯកឧត្តម ឧត្តមសេនីយ៍ឯក **លឿង តាមក្បាង** ដែលតែងយកចិត្តទុកដាក់ជំរុញដល់អាជ្ញាធរ និងកម្លាំងនគរបាលតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ និងកម្ពុជា-វៀតណាម ក្នុងការលើកកម្ពស់កិច្ចសហការជិតស្និទ្ធលើការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែន ជាពិសេស បទល្មើសគ្រឿងញៀន អំពើជួញដូរមនុស្ស និងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ៕

ថ្ងៃចន្ទ ៩រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៥